អង្គការទិន្នន័យអំពីការអភិវឌ្ឍ
Open Development Cambodia

www.opendevcam.net
OpenDevCam
@OpenDevCam
(+855) 23 902 196
contact@opendevcam.net

# សិក្ខាសាលាបណ្តុះបណ្តាលស្តីពី
# មូលដ្ឋានគ្រឹះនៃ GIS និងការប្រើប្រាស់ QGIS

## សេចក្តីផ្តើម៖

អង្គការទិន្នន័យអំពីការអភិវឌ្ឍ ហៅកាត់ថាអូឌីស៊ី គឺជាគេហទំព័របែប "ទិន្នន័យបើកទូលាយ"។ គេហទំព័រប្រភេទនេះ ជាគេហទំព័រដំបូងគេបង្អស់នៅតំបន់អាស៊ីអាគ្នេយ៍។ ចលនានៃ "ទិន្នន័យបើកទូលាយ" គឺផ្អែកលើការសន្មត់ដ៏សាមញ្ញមួយថា ទិន្នន័យ ឬព័ត៌មានទាំងឡាយណា ដែលត្រូវបានប្រមូលផ្តុំសម្រាប់ផលប្រយោជន៍សាធារណៈ គួរតែដាក់ឱ្យប្រើប្រាស់បានជាសាធារណៈ ពោលគឺដោយគ្មានការដាក់កំហិតឡើយ។ ព័ត៌មានឬ "ទិន្នន័យ" ទាក់ទងនឹងវិស័យសាធារណៈគួរផ្តល់ឱ្យដោយសេរីដល់គ្រប់ៗគ្នា ដើម្បីប្រើ និងធ្វើការផ្សព្វផ្សាយជាសាធារណៈតាមបំណងប្រាថ្នារបស់អ្នកប្រើប្រាស់។ អង្គការអូឌីស៊ីមិនធ្វើការលើកស្ទួយ ឬផ្សព្វផ្សាយទស្សនៈ របៀបវារៈ ឬការលម្អៀងណាមួយ ក្រៅពីការផ្តល់ព័ត៌មានជាសត្យានុម័តអំពីប្រទេសកម្ពុជានិងការអភិវឌ្ឍរបស់ប្រទេសនោះឡើយ។

អង្គការទិន្នន័យអំពីការអភិវឌ្ឍមានសេចក្តីសោមនស្សរីករាយក្នុងការរៀបចំសិក្ខាសាលាស្តីពីមូលដ្ឋានគ្រឹះ នៃប្រព័ន្ធព័ត៌មានភូមិសាស្ត្រ និងការប្រើប្រាស់ QGIS ដែលមានរយៈពេល ៣ ថ្ងៃ នៅថ្ងៃទី ០២-០៤ ខែសីហា ឆ្នាំ២០២៣ (ចាប់ពីម៉ោង ៨:០០ព្រឹក ដល់ម៉ោង ៤:៣០នាទីល្ងាច)។ សិក្ខាសាលានេះមានគោលបំណងផ្តល់ជូន នូវចំណេះដឹងអំពីប្រព័ន្ធព័ត៌មានភូមិសាស្ត្រ និងការប្រើប្រាស់កម្មវិធី QGIS សម្រាប់ការប្រមូលទិន្នន័យ ការគ្រប់គ្រងទិន្នន័យ និងការធ្វើផែនទី។

## សិក្ខាសាលា៖

សិក្ខាសាលារយៈពេលបីថ្ងៃនេះ ត្រូវបានរៀបចំឡើងដោយមានមេរៀនសម្រាប់សិក្ខាកាមយល់ដឹងអំពីគោលការណ៍សំខាន់ៗ នៃការប្រើប្រាស់ផែនទី និងការអនុវត្តជាក់ស្តែងក្នុងការងារ។ មេរៀនទាំងអស់រួមមាន៖
ជំពូក១ ៖ ការណែនាំអំពីប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS)
ជំពូក២ ៖ ការចាប់ផ្តើមដំបូងជាមួយកម្មវិធី QGIS
ជំពូក៣ ៖ ការគ្រប់គ្រងប្រព័ន្ធទិន្នន័យផែនទី
ជំពូក៤ ៖ ការរចនាទិន្នន័យតាមរយៈការដាក់ពណ៌ និងនិមិត្តសញ្ញា
ជំពូក៥ ៖ ការរាចនា និងផលិតផែនទី

## អំពីសិក្ខាសាលា៖

វគ្គបណ្តុះបណ្តាលរយៈពេលបីថ្ងៃនេះត្រូវបានបើកឱ្យសាធារណៈជនអាចដាក់ពាក្យបាន ហើយអ្នកចូលរួមដែលជានិស្សិតសាកលវិទ្យាល័យ យុវជន អង្គការក្រៅរដ្ឋាភិបាល និងមន្ត្រីរដ្ឋាភិបាលដែលការងារត្រូវការជំនាញ GIS ត្រូវបានផ្តល់អាទិភាពសម្រាប់ការជ្រើសរើសឱ្យចូលរួម។ សិក្ខាសាលានេះត្រូវបានរំពឹងថានឹងពង្រឹងជំនាញ GIS របស់អ្នកចូលរួម ដើម្បីបង្កើនគុណភាពការងាររបស់ពួកគេដែលទាក់ទងនឹង GIS ។
ទីតាំង៖ ជូនដំណឹងនៅពេលក្រោយ

www.opendevcam.net
OpenDevCam
@OpenDevCam
(+855) 23 902 196
contact@opendevcam.net

កាលបរិច្ឆេទ៖

- ថ្ងៃផុតកំណត់ចុះឈ្មោះ៖ ២៤ កក្កដា ២០២៣
- ថ្ងៃប្រកាសឈ្មោះបេក្ខជន៖ ២៦ កក្កដា ២០២៣
- ថ្ងៃបណ្តុះបណ្តាលៈ ០២-០៤ សីហា ២០២៣

អត្ថប្រយោជន៍៖ សិក្សាដោយឥតគិតថ្លៃ វិញ្ញាបនបត្រ អ៊ីនធឺណិត អាហារសម្រន់ និងអាហារថ្ងៃត្រង់

មេរៀនសិក្សា៖ ភាសាខ្មែរ និងអង់គ្លេស

តម្រូវការ៖ អ្នកចូលរួមត្រូវមាន កុំព្យូទ័រយួរដៃ ចំណេះដឹងក្នុងការប្រើប្រាស់កុំព្យូទ័រ និងភាសាអង់គ្លេសកម្រិតមូលដ្ឋាន (អាចយល់ពីពាក្យអង់គ្លេសទូទៅបាន)។

សម្រាប់ការចុះឈ្មោះ៖ https://bit.ly/43eJOOZ

ទំនាក់ទំនង៖ លោក ឡុច កល្យាណ ទូរសព្ទលេខ៖ (៨៥៥)៩៣ ៨៤ ២៩ ១៨

សារអេឡិចត្រូនិក៖ training@opendevcam.net

**ព័ត៌មានចូលរៀនដោយឥតគិតថ្លៃ៖**

អង្គការទិន្នន័យអំពីការអភិវឌ្ឍ (អូឌីស៊ី) និងផ្ដល់កន្លែងចំនួន២០ តាមរយៈការចុះឈ្មោះរបស់អ្នកចូលរួម ដោយអង្គការទិន្នន័យអំពីការអភិវឌ្ឍ (អូឌីស៊ី) ធ្វើការជ្រើសរើសចេញពីការចុះឈ្មោះនោះ ។